# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពុទ្ធភាសិតសំដែងអំពីជំនះលើបុគ្គលប្រព្រឹត្តអាក្រក់

www.hoksavann,com

ថ្ងៃទី២១ តុលា ២០១០



ពុទ្ធភាសិតសំដែងអំពីជំនះលើបុគ្គលប្រព្រឹត្តអាក្រក់ គឺបុគ្គលគប្បីឈ្នះមនុស្សក្រោធខឹងដោយពុំក្រោធខឹងតប គប្បីឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ គប្បីឈ្នះមនុស្សកំណាញ់ដោយការឲ្យ គប្បីឈ្នះមនុស្សនិយាយពាក្យពុំពិតដោយពាក្យពិត នេះចេញមកពីគាថាថា អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។

ពាក្យថា បុគ្គលគប្បីឈ្នះមនុស្សក្រោធខឹង ដោយពុំក្រោធខឹងតបបានសេចក្តីថា បុគ្គលណាម្នាក់បានទប់ចិត្តពុំក្រោធខឹងតបវិញ ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដែលបានក្រោធខឹងចំពោះខ្លួន ដោយវិធីអត់ឱនពុំខឹងតបវិញ ដោយប្រើចិត្តមេត្តា ។ ដោយប្រើវិធីនេះពុំយូរប៉ុន្មាន ជននោះអាចស្រាលចិត្តអន់កំហឹង ឬបាត់ខឹងតែម្តង ដោយឃើញភាពពុំមានប្រតិកម្មតបតមកខ្លួនវិញ ។ បើខឹងតបវិញ ហាក់ដូចជាយកអុសទៅដាក់បន្ថែមក្នុងភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ ។ ពាក្យថាឈ្នះគឺឈ្នះត្រង់ពុំខឹងតបនេះឯង ។ ប៉ុន្តែការបង្អន់កំហឹងចំពោះអ្នកខឹង ដោយមិនតបដោយកំហឹងនោះ បានចំពោះតែបុគ្គលខ្លះ និងចំពោះតែកំហឹងស្រាលៗ បើកំហឹងនោះឡើងដល់កំរិតខ្ពស់ហើយ ពុំអាចបង្អន់កំហឹងនោះបានឡើយ ។

ប៉ុន្តែអ្នកអត់ឱនបានលទ្ធផលសំខាន់ ត្រង់មិនចង់ឲ្យមានការចងពៀរនឹងគ្នាទៅមុខទៀត ។ អ្នកដែលមានកំហឹងបានដោយការពិចារណាទោសនៃកំហឹងនោះ ជាមួយនិងគុណសម្បត្តិនៃធម៌មេត្តា ។ ការទាស់ទែងខ្វែងគំនិតគ្នា រហូតដល់ប្រើហឹង្សាមកអំពីសេចក្តីក្រោធដែលជាក្រុមរបស់ទោសៈនោះឯង ។ ពុទ្ធសាសនាពោលថា សង្គមតូចសង្គមធំបើមានការបៀតបៀនគ្នាហើយ សង្គមនោះពុំបានសេចក្តីសុខសន្តិភាពឡើយ ។ តាមន័យនេះ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា គួរខ្មែរគ្រប់គ្នាកុំប្រើធម៌ហឹង្សា ទោះបីមានទំនាស់គ្នាក្នុងគ្រួសារក្តី ក្នុងបញ្ហានយោបាយរបស់ប្រទេសជាតិក្តី គួរប្រើវិធីសំរុះសំរួលគ្នា ចរចាគ្នាដោយសន្តិវិធី រក្សាឯកភាពជាតិ ដើម្បីរស់នៅជាមួយគ្នាដោយសុខសាន្ត រក្សាអត្តសញ្ញាណជាតិ ។ គួរយកអតីតកាលជាមេរៀនសំរាប់រៀបចំអនាគតឲ្យចំរើនរុងរឿងនៃប្រទេសកម្ពុជាមាតុភូមិ ។ តាមពុទ្ធភាសិតដូចពោលមកហើយនេះ សូមកុំយល់ច្រឡំអំពីពាក្យថា ពុំខឹងតប និងពាក្យថាសិទ្ធិការពារកម្មសិទ្ធិរបស់ខ្លួន ។ ការពុំខឹងតបតពុំមែនបានន័យថា គេរំលោភសិទ្ធិមានការរំលោភយកទឹកដីជាដើម ពុំការពារទុកបណ្តោយឲ្យគេយកតាមចិត្តនោះឡើយ ។ ផ្ទុយទៅវិញ ពុទ្ធសាសនាបានសំដែងឲ្យថែរក្សារបស់ដែលមាន និងស្វែងរករបស់ដែលបានបាត់បង់ ដែលបាលីថា អរក្ខសម្បទា ។

ពាក្យថា គប្បីឈ្នះមនុស្សអាក្រក់ដោយសេចក្តីល្អ ។ ពាក្យនេះមានន័យស្រដៀងគ្នានឹងពាក្យ កុំតបតដោយកំហឹងចំពោះមនុស្សមានកំហឹង ។ តាមធម្មតា មនុស្សអាក្រក់ បើធ្វើអាក្រក់តប មនុស្សអាក្រក់នឹងធ្វើអាក្រក់កាន់តែខ្លាំងឡើង ។ បើគេធ្វើអាក្រក់ ត្រូវព្យាយាមធ្វើល្អតបវិញ ជាមួយនិងការជួយណែនាំឲ្យលះអំពើអាក្រក់ដោយមេត្តាចិត្ត ជួនកាលមនុស្សអាក្រក់នេះអាចលះបង់អំពើអាក្រក់ ហើយចាប់ផ្តើមសាងល្អវិញ ។ បើមនុស្សនោះមានគំនិតពាលខ្លាំង នឹងមិនអាចកែគំនិតអាក្រក់មកល្អវិញបានឡើយ ។ នៅមង្គលសូត្រនៃគម្ពីរពុទ្ធសាសនាបានហាមសេពគប់បុគ្គលពាល ព្រោះបុគ្គលពាលទោះបីធ្វើល្អយ៉ាងណា ក៏បុគ្គលពាលមិនឲ្យសុខដែរ ត្រូវជៀសចេញឲ្យឆ្ងាយ ។ ប៉ុន្តែជ័យជំនះក្នុងពុទ្ធភាសិតនេះ គឺអ្នកប្រព្រឹត្តអាក្រក់ ពុំប្រព្រឹត្តអាក្រក់តបវិញ ទោះអ្នកនោះកែគំនិតអាក្រក់ក្តីមិនកែក្តី អ្នកប្រព្រឹត្តល្អពុំតបតពិតជាមានជ័យជំនះ ព្រោះពុំបានប្រព្រឹត្តអាក្រក់តបដែលជាហេតុនាំឲ្យមានទុក្ខទោសទៅមុខ ។

ពាក្យថា គប្បីឈ្នះមនុស្សកំណាញ់ដោយការឲ្យ បានសេចក្តីថា មនុស្សកំណាញ់ គឺមនុស្សជាប់ជំពាក់នឹងទ្រព្យសម្បត្តិរបស់ខ្លួនខ្លាំង មិនអាចលះបង់ឲ្យដល់អ្នកដទៃ ។ បើជនណាមួយឧស្សាហ៍ឲ្យវត្ថុផ្សេងៗដល់ជននោះ ថ្ងៃណាមួយជននោះនឹងរីករាយចិត្ត ហើយលះបង់នូវសេចក្តីកំណាញ់របស់ខ្លួន ហើយឲ្យនូវវត្ថុផ្សេងៗដល់ជននោះវិញ ដោយកើតគំនិតថា គេមានចិត្តល្អនឹងខ្លួនៗត្រូវតែមានចិត្តល្អនឹងគេវិញ ។

ពាក្យថា គប្បីឈ្នះមនុស្សនិយាយពាក្យពុំពិតដោយពាក្យពិត មានន័យថា ជនណាម្នាក់តែងតែនិយាយពាក្យពុំពិតនៅចំពោះមុខអ្នកដែលនិយាយតែពាក្យពិត នេះការពិតបានលេចចេញឡើង អ្នកនិយាយការពុំពិតនោះ ត្រូវចាញ់ខ្លួនឯង ខ្មាស់សំដីខ្លួនឯង ជាសំដីគ្មានតម្លៃ គេមិនជឿទុកចិត្ត ដូចពាក្យខ្មែរថា ពាក្យភូតចាញ់អាត្មា ។ ពាក្យខ្មែរមួយទៀតថា សំដីជាឯកគឺសំដីជាលេខមួយ ។ ពាក្យខ្មែរថា រនាបបាក់យករនាបជួស សំដីហួសគ្មានអ្វីជួសបានឡើយ ។ មនុស្សគេយកសំដី ដំរីគេយកភ្លុក ។ តាមព្រះពុទ្ធសាសនាពោលថា ដើម្បីដឹងមនុស្សល្អអាក្រក់ គេត្រូវពិនិត្យមើលសកម្មភាពការងារ មិនត្រូវស្តាប់ជឿសំដីតែម្យ៉ាងឡើយ ។៚

☆ ☆

☆